ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

# កំណត់ហេតុ

## កិច្ចប្រជុំពិគ្រោះយោបល់កម្រិតបច្ចេកទេស រវាងប្រទេសបញ្ជូនពលករទាំងបី កម្ពុជា ឡាវ មីយ៉ាន់ម៉ា អំពីតួនាទីរបស់ប្រទេសបញ្ជូនពលករ ដើម្បីពង្រឹងកិច្ចការពារពលករទេសន្តរប្រវេសន៍ ដែលប្រឈមនឹងហានិភ័យ ពីពលកម្មដោយបង្ខំ និងការជួញដូរមនុស្ស

ថ្ងៃទី ២៤-២៥ ខែឧសភា ឆ្នាំ២០១៨
ខេត្តសៀមរាប ព្រះរាជាណាចក្រកម្ពុជា

នៅថ្ងៃព្រហស្បតិ៍ ១០កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធស័ក ព.ស២៥៦២ ត្រូវនឹងថ្ងៃទី២៤ ខែឧសភា ឆ្នាំ ២០១៨ នៅសណ្ឋាគារសុខាល័យអង្គរ ខេត្តសៀមរាប មានបើកកិច្ចប្រជុំរយៈពេល ០២ថ្ងៃ ដើម្បីពិគ្រោះយោបល់កម្រិតបច្ចេកទេស រវាងប្រទេសបញ្ជូនពលករទាំងបី កម្ពុជា ឡាវ មីយ៉ាន់ម៉ា អំពីតួនាទីរបស់ប្រទេសបញ្ជូនពលករ ដើម្បីពង្រឹងកិច្ចការពារពលករទេសន្តរប្រវេសន៍ ដែលប្រឈមនឹងហានិភ័យ ពីពលកម្មដោយបង្ខំ និងការជួញដូរមនុស្ស ដែលភាគីកម្ពុជាដឹកនាំដោយ **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធាន អចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ភាគីឡាវដឹកនាំដោយ លោក Onevong Keobunnavong ប្រធានជួយកុមាររងគ្រោះដោយការជួញដូរ នៃនាយកដ្ឋានសុខមាលភាពសង្គម ក្រសួង ការងារ និងសុខមាលភាពសង្គម និង ភាគីមីយ៉ាន់ម៉ាដឹកនាំដោយ លោកស្រី Thin Pyant Thida Kyaw ទីប្រឹក្សា និងអនុប្រធានបេសកកម្ម នៃស្ថានទូតមីយ៉ាប្រចាំកម្ពុជា ។

## ក. សមាសភាពចូលរួមកិច្ចប្រជុំ

គណៈប្រតិភូកម្ពុជា មានចំនួន ១៩រូប ជាតំណាងមកពី ក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងសាលាខេត្តសៀមរាប ។

គណៈប្រតិភូឡាវ មានចំនួន ០៣រូប ជាតំណាងមកពី ក្រសួងការងារ និងសុខមាលភាពសង្គម ។

គណៈប្រតិភូមីយ៉ាន់ម៉ា មានចំនួន ០១រូប ជាតំណាងមកពី ស្ថានទូតមីយ៉ាប្រចាំកម្ពុជា ។

អង្គការ និងសង្គមស៊ីវិលមាន UN-Women, IOM, IJM, ILO, UN-ACT, JICA, USAID, GVC, LSCW, LPN, Hope for Justice, Winrock Int, Ratanak Int,Samaritan's purse, Chabdai Coalition, Wordvision Cambodia និង ACRA ។

## ២. កម្មវិធីបើក

ជាកិច្ចចាប់ផ្តើមបើកកម្មវិធី **លោកជំទាវ ជូ ប៊ុនអេង** បានមានប្រសាសន៍ស្វាគមន៍ និងថ្លែងអំណរគុណចំពោះការអញ្ជើញចូលរួមរបស់គណៈប្រតិភូឡាវ ភូមា និងកម្ពុជា ដែលជាមន្ត្រីបច្ចេកទេស មកពីបណ្តាក្រសួង អង្គភាពពាក់ព័ន្ធ អង្គការអន្តរជាតិ និងសង្គមស៊ីវិល ។ លោកជំទាវបានមានប្រសាសន៍បន្ត ដែលមានអត្ថន័យសង្ខេបដូចតទៅ៖ ដោយសារប្រទេសទាំងបីបាននិងកំពុងមានភាពប្រឈមដូចគ្នាលើបញ្ហាទេសន្តរប្រវេសន៍ជាពិសេសនៅប្រទេសថៃ និងដោយសារប្រទេសនីមួយៗមានរបៀបគ្រប់គ្រងបទដ្ឋាន និងនីតិវិធីក្នុងការអនុវត្តដោយឡែកពីគ្នា មានទាំងចំណុចល្អ ទាំងចំណុចខ្វះខាត ដូច្នេះកិច្ចប្រជុំនេះនឹងពិភាក្សាបើកចំហរដោយលក្ខណៈមិត្តភាព ដើម្បីរកឲ្យឃើញនូវបញ្ហាពិត និងត្រូវជ្រើសរើសបញ្ហាអាទិភាព ដើម្បីស្វែងរកដំណោះស្រាយដោយឡែកសម្រាប់អនុវត្តតាមប្រទេសរៀងខ្លួន និងដំណោះស្រាយរួមសម្រាប់អនុវត្តរួមទាំងបីប្រទេស ។ គោលបំណងសំខាន់ នៃកិច្ចប្រជុំនេះ គឺស្វែងយល់អំពីស្ថានភាព និងបទពិសោធន៍ល្អៗក្នុងការបញ្ជូនពលករ និងគ្រប់គ្រងលំហូរមិនប្រក្រតីនៃទេសន្តរប្រវេសន៍ ដែលជាប្រភពនៃអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចគ្រប់រូបភាព ជាពិសេសគឺកំណត់យុទ្ធសាស្ត្រ និងសកម្មភាពជាអាទិភាព ដើម្បីលើកជាអនុសាសន៍សំខាន់ៗជាក់ជូន និងស្វែងរកការគាំទ្រពីប្រមុខរដ្ឋាភិបាលទាំងបីប្រទេស ដើម្បីពិភាក្សា និងធ្វើការតស៊ូមតិជាមួយនឹងប្រទេសគោលដៅ ។ ដូច្នេះនៅពេល កំណត់រកដំណោះស្រាយរួមដែលសមស្របបានហើយ នឹងលើកយកទៅពិភាក្សាជាមួយប្រទេសថៃ ដែលជាប្រទេសគោលដៅ ដើម្បីរួមសហការគ្នាការពារពលករ និងលើកកម្ពស់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ (Safe, Orderly and Regular Migration) ទៅអនាគត ។ ក្នុងនាមគណៈកម្មាធិការជាតិប្រឆាំងការជួញដូរមនុស្សកម្ពុជា សង្ឃឹមថាកិច្ចពិភាក្សានេះនឹងទទួលបានលទ្ធផលផ្លែផ្កាដែលប្រតិភូនីមួយៗនឹងអាច យកទៅដាក់ជូនថ្នាក់ដឹកនាំទទួលបន្ទុកការងារប្រឆាំងការជួញដូរមនុស្ស និងការងារគ្រប់គ្រងទេសន្តរប្រវេសន៍ នៃប្រទេសរៀងខ្លួន ដើម្បីពិនិត្យ បំពេញបន្ថែម និងឈានទៅការជួបគ្នារវាងថ្នាក់ដឹកនាំប្រទេសទាំងបី ដើម្បីសម្រេច លើសេចក្តីថ្លែងការណ៍រួម លើដំណោះស្រាយរួម នៅពេលអនាគតដ៏ខ្លីខាងមុខ និងអាចដាក់ស្នើការពិភាក្សាជាមួយភាគីថៃ ក្នុងការរួមសហការគ្នាដោះស្រាយបញ្ហាពលករឲ្យបានល្អូន ។

**លោកជំទាវ សាន្ត អរុណ** រដ្ឋលេខាធិការក្រសួងកិច្ចការនារី បានមានប្រសាសន៍ស្វាគមន៍ និងថ្លែងអំណរគុណដល់គណៈប្រតិភូទាំងអស់ ។ លោកជំទាវបានមានប្រសាសន៍ថ្លែងអំណរគុណក្រុមការងារ COMMIT ដែលមាន ៦ប្រទេសបានជួបប្រជុំគ្នាជាច្រើនលើករួចមកហើយ ក្នុងនោះក៏មានប្រទេសឡាវ និងប្រទេសមីយ៉ាន់ម៉ា ហើយសង្ឃឹមថានឹងយកបទពិសោធន៍ពាក់ព័ន្ធមកចែករំលែកនាពេលនេះ ។ លោកជំទាវយល់ឃើញថា កន្លងមកប្រទេសយើងទាំងបីបានសហការគ្នាហើយ គ្រាន់តែការអនុវត្តនៅដាច់ដោយឡែករៀងខ្លួន ដូច្នេះត្រូវស្វែងរកការសហការរួមគ្នាឲ្យបានល្អប្រសើរ និងសូមជូនពរឲ្យកិច្ចប្រជុំពិភាក្សានេះទទួលបានជោគជ័យ ។

លោកស្រី SARAH KNIBBS (UN-Women) បានមានប្រសាសន៍ថា៖ ទេសន្តរប្រវេសន៍មានប្រយោជន៍ដល់ប្រទេសបញ្ជូន និងប្រទេសទទួល តែទន្ទឹមនោះក៏មានការកេងប្រវ័ញ្ច ជាពិសេសចំពោះស្ត្រី ដែលងាយស្រួលក្នុងការបោកបញ្ឆោត ជាពិសេសស្ត្រីធ្វើការងារផ្ទះមិនស្របច្បាប់ និងទទួលប្រាក់ឈ្នួលតិច ។ អង្គការ UN-Women រីករាយនឹងការចូលរួមប្រជុំពិភាក្សាដោះស្រាយបញ្ហាពលករទេសន្តរប្រវេសន៍នេះ ដែលការនិយាយជាចំហរអំពីទេសន្តរប្រវេសន៍មានសារសំខាន់ណាស់ ។

លោក Onevong Keobunnavong ប្រធានគណៈប្រតិភូឡាវ បានមានប្រសាសន៍ថា៖ ប្រទេសយើងទាំងបីជាប្រទេសមានពលកររច្រើននៅប្រទេសថៃ ហើយការជួបប្រជុំនាពេលនេះគឺដើម្បីស្វែងរកដំណោះស្រាយចំពោះបញ្ហាដែលបាននិងកំពុងជួបប្រទះដូចៗគ្នា និងជាឱកាសដែលយើងផ្តួចផ្តើមរកដំណោះស្រាយជួយគ្នាទៅវិញទៅមក ។ យើងក៏បានធ្វើការជាមួយ COMMIT តាំងពីឆ្នាំ២០០៤ ដើម្បីជួយពលករទេសន្តរប្រវេសន៍ និង

បានចុះកិច្ចព្រមព្រៀងក្នុងបំណងសហការជួយគ្នាឲ្យកាន់តែល្អប្រសើរ ។ ជាការពិត យើងបានធ្វើការងារនេះក្នុងអនុតំបន់ទន្លេមេគង្គ តែនីតិវិធីអនុវត្តជាក់ស្តែងមិនទាន់មាន មានតែការអនុវត្តតាមកិច្ចព្រមព្រៀង ។ ខ្ញុំសូមឲ្យរដ្ឋាភិបាលនៃប្រទេសទាំងបីរួមគ្នាដោះស្រាយ ហើយខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះកិច្ចប្រជុំនេះ និងសូមជូនពរឲ្យទទួលបានជោគជ័យ ជាពិសេសទទួលបានអនុសាសន៍ បទពិសោធន៍ និងដំណោះស្រាយល្អៗ ។

លោកស្រី Thin Pyant Thida Kyaw ប្រធានគណៈប្រតិភូមីយ៉ាន់ម៉ា បានមានប្រសាសន៍ថាៈ កិច្ចប្រជុំនេះនឹងផ្តល់ផលល្អជាខ្លាំងក្នុងការដោះស្រាយបញ្ហាពលករទេសន្តប្រវេសន៍ ដែលមានភាពស្មុគស្មាញច្រើនចំពោះប្រទេសបញ្ជូនទាំងបី ។ ៧០ភាគរយ នៃពលករមីយ៉ាន់ម៉ា រស់នៅតាមទីជនបទ និងមានការប្រែប្រួលតាមវិនិយោគបរទេស ហើយពួកគាត់ភាគច្រើនធ្វើទេសន្តប្រវេសន៍តាមរយៈគ្រួសារ និងការរៀបការ ។ ប្រទេសមីយ៉ាន់ម៉ា ជាប្រទេសមានពលករទេសន្តប្រវេសន៍ច្រើនជាងគេក្នុងអនុតំបន់ទន្លេមេគង្គ ដែលស្ត្រីត្រូវបានជួញដូរ និងបុរសត្រូវបានបញ្ជូនទៅការងារសំណង់ និងនេសាទ ។ កិច្ចប្រជុំបច្ចេកទេសនេះនឹងចែករំលែកបទពិសោធន៍ និងមេរៀនល្អៗ ហើយមីយ៉ាន់ម៉ានឹងចូលរួមសហការក្នុងការងារនេះ ។

## គ. ដំណើរការនៃកិច្ចពិភាក្សា

**វគ្គទី ១** : ស្ថានភាពទេសន្តប្រវេសន៍បច្ចុប្បន្នក្នុងប្រទេសថៃ និងផលប៉ះពាល់នៃការពង្រឹងការអនុវត្តច្បាប់ដោយអាជ្ញាធរថៃ

- បទបង្ហាញរបស់លោក Uy Akhara (IOM Phnom Penh): Risks and Rewards: Outcomes of Labour Migration in South-East Asia
  - ការសិក្សានេះបានធ្វើឡើងដោយ ILO TRIANGLE ក្នុងកម្មវិធីអាស៊ាន និងកម្មវិធី Rapid Asia ។
  - ចំណាកស្រុកដែលធ្វើដំណើរទៅកាន់ប្រទេសដទៃក្នុងតំបន់អាស៊ាន បានកើនឡើងច្រើនជាងប្រាំដងចាប់តាំងពីឆ្នាំ 1990 ដែលឈានដល់ជិត 6,9 លាននាក់ ។
  - របកគំហើញនៃការសិក្សាបង្ហាញថា ទោះបីជាផលប្រយោជន៍សេដ្ឋកិច្ចសង្គមនៃការធ្វើចំណាកមិនត្រូវបានពង្រីកជាអតិបរមានៅក្នុងតំបន់អាស៊ានក៏ដោយ ក៏លទ្ធផលវិជ្ជមានអាចសម្រេចបានប្រសិនបើពលករត្រូវបានផ្តល់ឱកាសបង្កើនជំនាញការងារ ជៀសវាងបំណុល ទទួលបានប្រាក់ឈ្នួលអប្បបរមា និងស្វែងរកការងារដែលទទួលបានផលចំណេញនៅពេលត្រឡប់វិញ ។ វិសាលភាពដ៏ធំដែលធ្វើអោយទទួលបានផលវិជ្ជមាន គឺតម្រូវឲ្យមានការផ្លាស់ប្តូរគោលនយោបាយ និងការអនុវត្តដោយរដ្ឋាភិបាល និយោជក និងទីភ្នាក់ងារជ្រើសរើសពលករ ជាជាងទៅលើអាកប្បកិរិយារបស់ពលករ ។ ដើម្បីគាំទ្រដល់ការសម្រេចបាននូវលទ្ធផលវិជ្ជមានកាន់តែច្រើន គឺត្រូវការផ្លាស់ប្តូរអភិបាលកិច្ចទេសន្តរ ប្រវេសន៍ការងារក្នុងអាស៊ាន ដែលនឹងធ្វើឲ្យចំនួនពលករទេសន្តរប្រវេសន៍មានបទពិសោធន៍ទទួលបានផលប្រយោជន៍មានចំនួនកើនឡើង ។

  **អនុសាសន៍ៈ**
  - អភិវឌ្ឍបណ្តាញអន្តោប្រវេសន៍ស្របច្បាប់ ដែលប្រើពេលវេលាខ្លី មិនស្មុគស្មាញ និងមិនចំណាយច្រើន
  - ផ្លាស់ប្តូរការចំណាយសម្រាប់ការជ្រើសរើសបុគ្គលិក ពីកម្មករទៅនិយោជក
  - ធានាថាពលករអន្តោប្រវេសន៍ស្ត្រី និងបុរសត្រូវបានគ្របដណ្តប់យ៉ាងពេញលេញដោយច្បាប់ការពារពលកម្ម និងសង្គម ដោយមិនគិតពីវិស័យការងាររបស់ពួកគាត់
  - ពង្រឹងផលប្រយោជន៍គាំពារសង្គមដល់ពលករ

- ពង្រីកការទទួលបានយុត្តិធម៌សម្រាប់ពលករ
- អនុវត្តការដាក់ទណ្ឌកម្មតឹងរ៉ឹងជាងមុនចំពោះនិយោជក និងភ្នាក់ងារជ្រើសរើសពលករ ដែលរំលោភសិទ្ធិរបស់ពលករ
- ផ្តល់ការបណ្តុះបណ្តាលជំនាញដែលស្របតាមតម្រូវការរបស់និយោជក និងបើកសុពលភាពជំនាញសម្រាប់កម្មករមានជំនាញទាប និងពាក់កណ្តាលជំនាញ
- ពង្រីកសេវាកម្មដែលផ្តល់ជូនដល់ពលករទេសន្តរប្រវេសន៍ សម្រាប់ការបញ្ជូនត្រឡប់ និងការធ្វើសមាហរណកម្ម ។

- បទអន្តរាគមន៍របស់លោក Onevong Keobunnavong ប្រធានគណៈប្រតិភូឡាវ : **បញ្ហាប្រឈម**
  - ទេសន្តរប្រវេសន៍បានជួបនូវបញ្ហាប្រឈមជាច្រើន ហើយយើងបានស្រាវជ្រាវឃើញថាមានខ្លះត្រឹមត្រូវ និងខ្លះមិនត្រឹមត្រូវ ។ រដ្ឋាភិបាលឡាវបានខិតខំធ្វើការទប់ស្កាត់មិនឲ្យចេញទៅដោយខុសច្បាប់ ព្រោះវានាំឲ្យមានបញ្ហាដល់សង្គមជាច្រើន ។ តាមការសិក្សាស្រាវជ្រាវ បើមិនទប់ស្កាត់ទេនឹងមានបញ្ហា ២សំខាន់គឺៈ ១.ទទួលប្រាក់ឈ្នួលមិនយុត្តិធម៌ ២.មិនមានការធានាក្នុងការងារ ។
  - បញ្ហាធំ ៣ ដែលបានជួបប្រទះមានៈ ១.ពលករគ្មានជំនាញទទួលប្រាក់ឈ្នួលតិច ២.ប្រទេសរីកចម្រើនតែងអូសទាញពលករពីប្រទេសផ្សេងៗ ៣.ការចេញទៅមិនមានភាពងាយស្រួល ។
  - ពលករឡាវក៏ជួបបញ្ហាការចំណាយតាមច្រកចេញ និងច្រករបៀងតូចៗ ហើយអ្វីដែលពលករសង្ឃឹមចង់បាន មិនបានតាមតម្រូវការនោះទេ តែងមានបញ្ហាជាច្រើនដូចជា គ្រោះថ្នាក់ចរាចរ និងចំណាយកើនឡើងជាដើម ។
  - យើងត្រូវរៀបចំនីតិវិធីផ្តល់ភាពងាយស្រួលដល់ពលករចេញទៅដោយស្របច្បាប់ និងទទួលកំរៃតាមការកំណត់ ។
  - ពលករក្រីក្រត្រូវការការគាំទ្រពីនិយោជក ដូច្នេះយើងត្រូវជ្រើសរើសពលករតាមក្រុមហ៊ុនស្របច្បាប់ឲ្យបានត្រឹមត្រូវ និងជំរុញឲ្យក្រុមហ៊ុនបង្កើនការអនុវត្តតាមផែនការ ។

- បទអន្តរាគមន៍របស់លោក Chhot Thany (LPN): **ការអនុវត្តច្បាប់ដោយអាជ្ញាធរថៃ**
  - ចំនួនពលករមានឯកសារស្របច្បាប់នៅថៃមានពី៥ទៅ៦លាននាក់ ពលករមានប័ណ្ណស៊ីជម្ពូមាន២លាននាក់ ។ ថៃបានធ្វើការពន្យាការផ្តល់ភាពស្របច្បាប់រហូតដល់ថ្ងៃទី៣០ ខែមិថុនា ហើយនឹងរៀបចំឲ្យពលករទៅធ្វើការស្របច្បាប់នៅប្រទេសថៃ ដែលខាងកម្ពុជា និងឡាវបានបំពេញការងារនេះបានល្អ ។ ពលករខ្លះមិនទាន់បានទទួលភាពស្របច្បាប់ បានឆ្លៀតឱកាសធ្វើការនៅកន្លែងផ្សេង ។ ពលករដែលមិនស្របច្បាប់ ឬមិនមានឯកសារគ្រប់គ្រាន់ ត្រូវទទួលពិន័យ ឬឃាត់ខ្លួន ។
  - ថៃបានរៀបចំច្បាប់ ឲ្យនិយោជកចេញលិខិតទទួលស្គាល់ពលករ តែក៏នៅមានអ្នកលួចលាក់ ដែលនាំឲ្យថៃនៅមានភាពអនាធិបតេយ្យ ។ កន្លែងមានចំណូលខ្ពស់ក៏មានពុករលួយច្រើន ។ ពលករខុសច្បាប់មិនហ៊ានចេញក្រៅ គឺទិញអាហារតែក្នុងកន្លែងធ្វើការ ដែលនាំឲ្យនិយោជកងាយកេងប្រវ័ញ្ច ។ ពលករធ្វើការក្រោមដីខ្លះបាត់ខ្លួន និងពលករផ្នែកនេសាទខ្លះលក់ទឹកស្លាប់ ។
  - បច្ចុប្បន្នអាយុ ១៨ឆ្នាំឡើងទើបអាចចូលទៅធ្វើការបាន តែនៅមានលួចដាក់អាយុលើស ។ ចំពោះក្រុមហ៊ុន បើនាំពលករចូលត្រូវមានឯកសារច្បាស់លាស់ (កន្លងមកក្រុមហ៊ុនខ្លះបានបោកពលករឲ្យចូលទៅប្រទេសថៃដោយខុសច្បាប់ រួចព្រលែងចោល ហើយត្រូវប៉ូលីសចាប់បញ្ជូនមកវិញ)

ដូច្នេះក្រុមហ៊ុនត្រូវធ្វើរបាយការណ៍ពីដំណើររបស់ពលករ ។ ឈ្មួញកណ្តាលទទួលលុយពីនិយោជក ដែលនាំឲ្យពលករទទួលបានប្រាក់ឈ្នួលតិច ។

- មានបញ្ហាលំបាកជាខ្លាំងចំពោះក្រុមហ៊ុននេសាទ ដោយរដ្ឋាភិបាលតម្រូវឲ្យធ្វើរបាយការណ៍ឲ្យបានច្បាស់លាស់ តែប៉ុន្មានឆ្នាំកន្លងមកពេលចុះពិនិត្យបង្ហាញតែអ្នកមានឯកសារ ពេលសមត្ថកិច្ចចេញបាត់ក៏មានលួចលាក់ដដែល ។
- ពួកមេខ្យល់ភាគច្រើនជាគ្នាឯង ឬមកពីប្រទេសខ្លួនឯង ហើយមានបោះត្រាក្លែងក្លាយលើឯកសារ ដើម្បីបានលុយពីពលករ ដែលជាហេតុនាំឲ្យមានបញ្ហាដល់ថៅកែ ។
- បច្ចុប្បន្នរដ្ឋាភិបាលថៃមានការរឹតបន្តឹង ដែលនាំឲ្យមានពលករខ្លះរត់ ខ្លះបាត់ខ្លួន ។ បើពលករមានបញ្ហា គេនឹងបញ្ជូនទៅអ្នកច្បាប់សាធារណៈ ហើយបច្ចុប្បន្នពលករមួយចំនួននៅកន្លែងស្នាក់នៅបណ្តោះអាសន្ន ។
- អង្គការមកពីកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា បានជួបពិភាក្សាគ្នាថា បើមានករណីគឺជួយគ្នាដោះស្រាយ ។
- យើងបានធ្វើសិក្ខាសាលាអំពីស្ត្រី និងកុមារ ក្នុងការបញ្ជូនឲ្យមានសុវត្ថិភាព និងសិក្ខាសាលាស្វែងរកដំណោះស្រាយឲ្យដំណើរការល្អផងដែរ ។

**ខណ្ឌទី ២** : <u>ចំណុចខ្វះខាត បញ្ហាប្រឈម និងការអនុវត្តល្អនៃយន្តការមានស្រាប់ គោលនយោបាយ និងក្របខ័ណ្ឌអភិបាលកិច្ចទេសន្តរប្រវេសន៍ការងារ និងបញ្ញត្តិស្តីពីដំណើរការផ្តល់ភាពស្របច្បាប់</u>

- បទបង្ហាញរបស់លោក អ៊ុក វ៉ារុជ (ក្រសួងការងារ): Strengthening Protection of At-Risk Migrants Against Forced Labor and Human Trafficking
  - កម្ពុជាបានបញ្ជូនពលករទៅប្រទេសថៃ កូរ៉េ ជប៉ុន ម៉ាឡេស៊ី សឹង្ហបុរី ហុងកុង និងអាប៊ីសាអូឌីត ហើយបានផ្ញើប្រាក់មកគ្រួសារសរុបជាង ១,៧ពាន់លានដុល្លា ។ មកទល់ឆ្នាំ២០១៧ មានពលករកម្ពុជាទៅធ្វើការនៅបរទេសចំនួន ១លាន២សែននាក់ ក្នុងនោះ៖
    - ប្រទេសថៃ ១.០៥៦.៣៥៨នាក់ ទទួលប្រាក់ឈ្នួលជាមធ្យម ២៥០ដុល្លាក្នុង១ខែ
    - ប្រទេសកូរ៉េ ៤៤.២២៩នាក់ ទទួលប្រាក់ឈ្នួលជាមធ្យម ១.២០០ដុល្លាក្នុង១ខែ
    - ប្រទេសជប៉ុន ៦.០០០នាក់ ទទួលប្រាក់ឈ្នួលជាមធ្យម ១.៥០០ដុល្លាក្នុង១ខែ
    - ប្រទេសម៉ាឡេស៊ី ៣០.០០០នាក់ ទទួលប្រាក់ឈ្នួលជាមធ្យម ២៤០ដុល្លាក្នុង១ខែ
    - ប្រទេសសឹង្ហបុរី ៤៨៧នាក់ ទទួលប្រាក់ឈ្នួលជាមធ្យម ៤៥០ដុល្លាក្នុង១ខែ
    - ប្រទេសហុងកុង ១៥នាក់ ទទួលប្រាក់ឈ្នួលជាមធ្យម ៥៥០ដុល្លាក្នុង១ខែ
    - ប្រទេសអារ៉ាប៊ីសាអូឌីត ១២នាក់ ។
  - នៅប្រទេសកម្ពុជាមាន ភ្នាក់ងារជ្រើសរើសឯកជន ៨០, ភ្នាក់ងារជ្រើសរើសសាធារណៈ(MTOSB), សមាគមន៍ ACRA និង MAC ។ ពលករត្រូវបានទទួលការបណ្តុះបណ្តាលពមុនចាកចេញ ។
  - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានរៀបចំ អនុក្រឹត ប្រកាស និងអនុស្សារណៈយោគយល់គ្នាជាមួយប្រទេសពាក់ព័ន្ធជាច្រើន ព្រមទាំងមាន គោលនយោបាយទេសន្តរប្រវេសន៍ការងារ (២០១៤-២០១៨ និង) គោលនយោបាយការងារជាតិ (២០១៥-២០២៥) ។
  - វិធានការការពារពលករទេសន្តរប្រវេសន៍ របស់ក្រសួងការងារ មានដូចជា៖
    - បណ្តុះបណ្តាល និងបញ្ជូនអ្នកប្រឹក្សាពលករទៅបរទេស
    - ពង្រឹងសេវាប្រឹក្សាដើម្បីគាំទ្រពលករទេសន្តរប្រវេសន៍
    - វិធានការដាក់ទណ្ឌកម្ម និងពិន័យ

- អភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលមុនចាកចេញ
- បង្កើតច្រកចេញចូលតែមួយ
- បង្កើតសម្ភារៈអប់រំពលករដូចជា សៀវភៅណែនាំវិវឌ្ឍ
- អប់រំអំពីការគ្រប់គ្រងហិរញ្ញវត្ថុ ជាពិសេសការផ្ទេរប្រាក់នៅថ្នាក់មូលដ្ឋាន
- គាំទ្រការបើកគណនីធនាគារដោយពលករទេសន្តរប្រវេសន៍នៅកម្ពុជា និងនៅប្រទេសគោលដៅ ដើម្បីជួយសម្រួលការផ្ទេរប្រាក់ ។

- បទអន្តរាគមន៍របស់លោក Onevong Keobunnavong ប្រធានគណៈប្រតិភូឡាវ :
  - នៅពេលជួបបញ្ហានៅប្រទេសថៃ យើងបានយកមកពិភាក្សា និងស្រាវជ្រាវ ។
  - ពលករមានកម្រិតយល់ដឹងទាប មិនចេះសរសេរអក្សរ ដែលតម្រូវឲ្យក្រុមហ៊ុនឆ្លៀតឱកាសជួយបំពេញពាក្យស្នើសុំ ដោយយកថ្លៃសេវា ។
  - បញ្ហារត់ការធ្វើឯកសារមានរយៈពេលយូរ និងមានតម្លៃខ្ពស់ ។
  - ពលករឡាវដែលទៅដោយខុសច្បាប់មានចំនួនច្រើន ហើយយើងក៏បានចចារជាមួយថៃ និងជួយបានមួយចំនួន តែមិនទាន់បានទាំងអស់នោះទេ ។
  - នៅឆ្នាំ២០០១ មានជនរងគ្រោះដោយអំពើជួញដូរមនុស្សចំនួន ២.៦០០នាក់ ភាគច្រើនជាពលករដែលត្រូវបានបង្ខិតបង្ខំ ។
  - ក្នុងរយៈពេល ២ឆ្នាំចុងក្រោយនេះ ចំនួនជនរងគ្រោះមានការថយចុះ ។
  - នៅឡាវមានក្រុមហ៊ុនបញ្ជូនពលករ ៩ តែមានតែ ៣ទេ ដែលបានអនុវត្ត និងសហការក្នុងការបញ្ជូនពលករ ហើយឥឡូវកំពុងតែបញ្ជូន តែក៏មានឧបសគ្គមួយចំនួនផងដែរ ។
  - បច្ចុប្បន្នពលករឡាវក៏កំពុងធ្វើការចុះបញ្ជីស្របច្បាប់ដែរ ហើយរដ្ឋាភិបាលឡាវ និងថៃក៏បានព្រមព្រៀងអនុវត្តការងារនេះផងដែរ ។
  - នៅមាន ២ចំណុចសេសសល់គឺៈ យុត្តិធម៌ និង ការចំណាយរបស់ពលករ ។

- បទអន្តរាគមន៍របស់លោកស្រី Thin Pyant Thida Kyaw ប្រធានគណៈប្រតិភូមីយ៉ាន់ម៉ាៈ
  - មីយ៉ាន់ម៉ាមានគោលនយោបាយពលករទេសន្តរប្រវេសន៍ធ្វើការនៅបរទេស ហើយក៏បានពង្រាងច្បាប់ដើម្បីការពារផលប្រយោជន៍ពលករផងដែរ ។
  - មីយ៉ាន់ម៉ាបានចុះអនុស្សារណៈជាមួយថៃក្នុងឆ្នាំ២០០៣ តែមិនអាចគ្របដណ្តប់បានទាំងស្រុងទេ ។
  - ក្រុមហ៊ុនបានបញ្ជូនពលករជាង ៧០ម៉ឺននាក់ ហើយទទួលការបណ្តុះបណ្តាលឥតគិតថ្លៃ ។
  - យើងមានក្រុមការងារចុះបញ្ជី និងការពារសិទ្ធិពលករ ។
  - មជ្ឈមណ្ឌលធនធានត្រូវបានបង្កើតដោយ ILO និង IOM ដើម្បីផ្តល់ព័ត៌មានដល់ពលករ ។

- បទអន្តរាគមន៍របស់លោក ដាញ់ អេងកក្កដា (ACRA):
  - បញ្ហាប្រឈមគឺនៅតែមានពលករទៅមិនស្របច្បាប់(មកពីមានអ្នកទទួលទើបមានអ្នកទៅ) ។ អ្នកខ្លះទៅតាមក្រុមហ៊ុន តែពេលដល់គោលដៅត្រូវបានគេអូសទាញទៅបន្ត ដែលនាំឲ្យក្រុមហ៊ុនជួបបញ្ហា ។
  - ក្រុមហ៊ុនជាសមាជិកត្រូវមានក្រមសីលធម៌ត្រឹមត្រូវ និងត្រូវបណ្តុះបណ្តាលពលករមុនចាកចេញ ។
  - ដៃគូជាមួយអង្គការ និងសមាគមន៍ពាណិជ្ជកម្មនៅប្រទេសផ្សេងៗ ដើម្បីបណ្តុះបណ្តាល និងបង្កើនការយល់ដឹង ។
  - វាយតម្លៃខ្លួនឯងថា អ្វីដែលមានស្របច្បាប់ ឬមិនស្របច្បាប់ ។
  - ដៃគូជាមួយរដ្ឋាភិបាល និងស្ថានទូត ក្នុងការប្រឆាំងការជួញដូរមនុស្ស និងការពារពលករ ។

- បណ្តុះបណ្តាលសមាជិកដែលស្របច្បាប់ សម្រាប់ការជ្រើសរើស និងបញ្ជូនដោយសុវត្ថិភាព ។
- ដៃគូជាមួយអង្គការ និងស្ថាប័នពាក់ព័ន្ធ អភិវឌ្ឍពលករគ្មានជំនាញ និងការទទួលស្គាល់ជំនាញ ។

## សំណួរ និងចម្លើយ

សំនួរ (UN-Women) : ពីមុនមានតែស្ត្រីចេញទៅម៉ាឡេស៊ី ឥលូវក៏មានបុរសដែរ តែស្ត្រីលំបាកជាងបុរស ទទួលបានប្រាក់ឈ្នួលតិច និងត្រូវចំណាយលើសុខភាពជាងបុរស ។ សំណូមពរឲ្យយកចិត្តទុកដាក់បន្ថែមលើស្ត្រី គួរមានថវិកាលើកទឹកចិត្តខ្ពស់ដល់ស្ត្រីមានផ្ទៃពោះ ។

ចម្លើយ (ក្រសួងការងារ) : ពលករទៅប្រទេសណាក៏ដោយតែងមានច្បាប់ស្តីពីការងារ ដែលចែងជារួមមិនថាបុរសឬស្ត្រីឡើយ គឺធ្វើតាមស្តង់ដាការងារតែមួយ (ស្ត្រីដែលបានប្រាក់ឈ្នួលតិចអាច មកពីតួនាទីការងារតូចជាងបុរស) ។

សំនួរ (LSCW) : ការធ្វើឯកសារមានរយៈពេលយូរ ស្មុគស្មាញ នាំឲ្យពលករទៅរកភ្នាក់ងារ ដូចនេះចង់ឲ្យនិយោជកបង់ថ្លៃសេវាជ្រើសរើសទៅឲ្យក្រុមហ៊ុនជំនួសពលករ តើយើងអាចយកទៅចរចាជាមួយថៃបានទេ?

ចម្លើយ (ក្រសួងការងារ) : ឲ្យតែមានអនុស្សារណៈ យើងតែងពិភាក្សាអំពីប្រាក់ឈ្នួលអប្បរមា ដែលការចំណាយ មានខ្ទង់របស់វា ដូចជានិយោជកត្រូវបង់មកឲ្យប្រទេសបញ្ជូនជាដើម ហើយយើងកំពុងសហការជាមួយ ILO ឲ្យមានការចេញតម្លៃនេះ ។

សំនួរ (CHABDAI) : តើក្រសួងការងារកម្ពុជា មានអ្វីវាស់វែងប្រាក់ដែលពលករផ្ញើរចូលមក?

ចម្លើយ (ក្រសួងការងារ) : ពលករនៅកូរ៉េ គេយកចំណូលជាមធ្យមតាមរយៈ ADB , World Bank ។ល។

សំនួរ (UN-ACT) : តើឡាវ និងមីយ៉ាន់ម៉ា មានកុមារចេញទៅថៃច្រើនទេ?

ចម្លើយ (LAO) : ច្បាប់មិនអនុញ្ញាតឲ្យអាយុក្រោម១៨ឆ្នាំចេញទៅទេ តែនៅតែមានលួចចេញ ។

(MYANMAR) : ច្បាប់មិនអនុញ្ញាតឲ្យអាយុក្រោម១៨ឆ្នាំចេញទៅទេ តែពលករមីយ៉ាន់ម៉ាភាគច្រើននៅតាមទីជនបទ ពេលចេញទៅជិះរទេះគោទៅទាំងគ្រួសារឆ្លងកាត់ព្រំដែន ។

សំនួរ (UN-ACT) : តើករណីកើតនៅអារ៉ាប៊ីសាអូឌីត ត្រូវបញ្ជូនទៅខាងណា?

ចម្លើយ (ក្រ.ការបរទេស) : ករណីកើតនៅអារ៉ាប៊ីសាអូឌីតដែលយើងគ្មានទូតនៅទីនោះ គឺត្រូវបញ្ជូនទៅទូតដែលតាំងនៅប្រទេសជិតនោះ ។

សំនួរ (UN-ACT) : បើដល់ថ្ងៃផុតកំណត់ផ្តល់សុពលភាព តែនៅផ្តល់មិនទាន់អស់ តើថៃមានវិធានការបែបណា?

ចម្លើយ (LPN) : យើងមានយុទ្ធសាស្ត្របង្កើតជាលេខទូរស័ព្ទ ដើម្បីឲ្យពួកគាត់ទំនាក់ទំនងមក មិនថាមកតាមក្រុមហ៊ុន ឬមកដោយខ្លួនឯងក៏ដោយ ដូចនេះពលករត្រូវបញ្ជូនព័ត៌មានដោយខ្លួនឯង ។

(ក្រសួងការងារ) : ការបញ្ចប់ជាគោលការណ៍របស់ក្រសួង ហើយកម្ពុជា-ថៃប្តេជ្ញាថានឹងបញ្ចប់នៅត្រឹមថ្ងៃទី៣០មិថុនា ។ យើងខិតខំផ្សព្វផ្សាយណាស់ដល់ពលករ ឥលូវព័ត៌មានថានៅសល់ ៨ម៉ឺននាក់ទៀត ហើយយើងនឹងសុំឲ្យអាជ្ញាធរភូមិឃុំធ្វើការរឹតបន្តឹង ។ កម្ពុជា-ថៃសន្យារៀបចំប្រព័ន្ធបញ្ជូនទិន្នន័យជាមួយគ្នាតាមប្រព័ន្ធអេឡិចត្រូនិច និងកំពុងបង្កើតក្រុមបច្ចេកទេស ។

## សំណូមពរ

(UN-ACT) : ចង់ឲ្យដាក់ដំណោះស្រាយគន្លឹះទាក់ទងនឹងការចំណាយ household ផង ។

**ចំណុចទី ៣** : ការបែងចែកក្រុមពិភាក្សា ដើម្បីកំណត់ពីបញ្ហាប្រឈម/បញ្ហាសំខាន់ៗ ដែលប្រទេសទាំងបីកំពុងជួបប្រទះ

ក្រុមទី១ ៖ យន្តការ ឬប្រព័ន្ធការពារពលករទេសន្តរប្រវេសន៍ ដែលប្រឈមនឹងហានិភ័យ

- នៅពេលផុតកំណត់ថ្ងៃផ្តល់ឯកសារស្របច្បាប់នៅថ្ងៃទី៣០ ខែមិថុនា ពលករដែលនៅតែមិនទាន់បានទទួលឯកសារច្បាប់នឹងត្រូវប្រឈមចំពោះការអនុវត្តច្បាប់របស់សមត្ថកិច្ចថៃ ។
- អ្នកកាន់ប័ណ្ណព័ណ៌ស៊ីជម្ពូមិនអាចពន្យាសុពលភាពបាន ។
- អ្នកចំណូលថ្មីដែលមិនទទួលបានឯកសារស្របច្បាប់នឹងក្លាយជាបញ្ហាបន្ថែមថ្មី ។
- ការគ្រប់គ្រងលំហូរពលករទេសន្តរប្រវេសន៍ឆ្លងកាត់ព្រំដែននៅមានកំរិត ។
- ដំណើរនៃការធ្វើឯកសារស្របច្បាប់មានភាពស្មុគ្រស្មាញ រយៈពេលយូរ និងមានតម្លៃថ្លៃ ។
- មិនមានការត្រួតពិនិត្យឲ្យបានច្បាស់លាស់ចំពោះពលករនៅលើទូកនេសាទ ។

ក្រុមទី២ ៖ ការទប់ស្កាត់

- ពលករនៅមានចំណេះដឹងទាបក្នុងការទទួលបានសារអប់រំរបស់យើង និងជាទូទៅតាមសហគមន៍ស្ត្រីចូលរួមតិចជាងបុរស ។
- អ្នកដែលមានចំណេះដឹង ជំនាញទាប ឬគ្មានជំនាញ ងាយចាញ់បោកគេ ឬត្រូវបានជួញដូរ ។
- និយោជកនៅតែប្រើប្រាស់ពលករមិនមានឯកសារ ដែលអាចកេងចំណេញដោយការផ្តល់ប្រាក់ឈ្នួលតិចជាដើម ។
- ពលករតែងមានបណ្តាញរបស់ខ្លួន គឺចេញតាមឈ្មួញកណ្តាល លឿន តែបើចេញតាម MOU មានលក្ខណៈស្មុគ្រស្មាញ ចំណាយពេលយូរ និងចំណាយលុយច្រើន ។
- ការគ្រប់គ្រងព្រំដែនមិនទាន់បានល្អ ដែលការគ្រប់គ្រងព្រំដែនទាមទារឲ្យមានកិច្ចសហការល្អរវាងប្រទេសបញ្ជូន និងប្រទេសទទួល ដោយអនុវត្តឲ្យបានត្រឹមត្រូវទាំងសងខាង ។
- ក្រុមហ៊ុនមួយចំនួនមិនល្អ ដោយមានការក្លែងបន្លំ និងស៊ីសំណូកជាដើម ដែលតម្រូវឲ្យមានការបណ្តុះបណ្តាលអំពីអាកប្បកិរិយាក្នុងការជ្រើសរើសពលករប្រកបដោយក្រមសីលធម៌ ព្រមទាំងពង្រឹង និងអភិវឌ្ឍជំនាញរបស់ពលករ ។
- ការងារទប់ស្កាត់បានធ្វើច្រើនហើយ តែមិនទាន់បានវាស់វែង ថាតើសកម្មភាពទប់ស្កាត់មានផលល្អប៉ុនណា? ជួយបានកំរិតណា? សំណួមពរឲ្យគិតគូរទាំងប្រទេសទទួល និងប្រទេសបញ្ជូន ។
- លំហូរពលករទេសន្តរប្រវេសន៍បានក្លាយជាទាសភាពសម័យទំនើប ដែលមានលេចចេញជាបញ្ហាជាច្រើនដូចជាការជួញដូរ និងការកេងប្រវ័ញ្ចកម្លាំងពលកម្មជាដើម ដែលតម្រូវឲ្យយើងត្រូវកំណត់បញ្ហា ឲ្យបានច្បាស់ ដើម្បីមានវិធានការការពារ និងសហការទប់ស្កាត់ ឈានទៅការបញ្ចប់នូវទាសភាពសម័យទំនើបនេះ ។

ក្រុមទី៣ ៖ ការការពារជនរងគ្រោះ

- នៅមានបញ្ហាចំពោះការទំនាក់ទំនង និងចែករំលែកព័ត៌មាន រវាងប្រទេសបញ្ជូន និងប្រទេសទទួល ថាតើធ្វើតាមបណ្តាញអ្វី ក្រសួងការបរទេស ឬអង្គការដៃគូផ្លូវការ ។ល។
- ការផ្តល់សេវាផ្នែកច្បាប់ទៅវិញទៅមកមាននៅថ្នាក់អាស៊ាន តែកិច្ចសហការមិនទាន់បានល្អ ។
- ការសហការរបស់ក្រុមហ៊ុនក្នុងការជួយជនរងគ្រោះមិនទាន់បានល្អ ។

- ការឃុំឃាំងពលករ ឬដាក់ក្នុងមណ្ឌលកែប្រែ នៅមានបញ្ហាជាច្រើនដូចជា ដំណើរការផ្លូវច្បាប់រយៈពេលយូរ នាំឲ្យមានបញ្ហាសុខភាព បាត់បង់ចំណូល ពិបាកទំនាក់ទំនងគ្រួសារ និងមានការលំបាកជាច្រើនទៀត ។
- ដំណើរការកំណត់អត្តសញ្ញាណជនរងគ្រោះ ប្រើរយៈពេលយូរ នៅប្រទេសម៉ាឡេស៊ីមានរយៈពេល ៦ខែទៅមួយឆ្នាំ ។ ក្នុងករណីរកឃើញថាមិនមែនជាជនរងគ្រោះ ក៏ត្រូវប្រឈមនឹងការចាប់បញ្ជូន ត្រឡប់មកស្រុកវិញដែរ ។
- យន្តការនៃការបញ្ជូនមិនទាន់ស៊ីសង្វាក់គ្នា ការកំណត់អត្តសញ្ញាណមិនស្របគ្នារវាងប្រទេសដើម និងប្រទេសគោលដៅ ។
- ដំណើរការតុលាការក្នុងសំណុំរឿងជនរងគ្រោះមានភាពស្មុគស្មាញ និងមានរយៈពេលយូរ ។ ពេលកាត់ក្តីរួមមានភាគតិចណាស់ទទួលបានសំណង ។
- បញ្ហាអត្តសញ្ញាណត្រូវបានផ្លាស់ប្តូរ ដូចជាពលករលើទូកនេសាទកាន់ប័ណ្ណពលករនេសាទសមុទ្រ (Seaman book) ដែលត្រូវបានប្តូរឈ្មោះ និងអត្តសញ្ញាណទៅជាជនជាតិថៃ ដូច្នេះការកំណត់អត្តសញ្ញានមានការលំបាក ។
- បញ្ហាជនរងគ្រោះ មិនសហការ គឺជនរងគ្រោះខ្លះមិនដឹងថាខ្លួនឯងកំពុងរងគ្រោះ ។
- <u>**ឡាវ**</u> ៖ ទាក់ទងនឹងមណ្ឌលទទួលពលករនៅថៃ នៅពេលគេកំណត់ថាជាជនរងគ្រោះ គេនឹងយកទៅដាក់ក្នុងមណ្ឌល ហើយគេនឹងបណ្តុះបណ្តាល និងទំនាក់ទំនងទៅគ្រួសារ ។ ជនរងគ្រោះខ្លះត្រឡប់មកប្រទេសវិញពីរបីឆ្នាំ ស្រាប់តែមានលិខិតអញ្ជើញទៅដោះស្រាយករណីនៅតុលាការថៃ (យើងមិនមានចំណាយសម្រាប់គាត់) ហើយក្រោយកាត់ក្តី ភាគីថៃមិនបានបញ្ជូនទិន្នន័យមកទេ ។
- <u>**មីយ៉ាន់ម៉ា**</u> ៖ ពលករមីយ៉ាន់ម៉ាឆ្លងកាត់ការកំណត់អត្តសញ្ញាណជនរងគ្រោះនៃថៃ ប្រហាក់ប្រហែលនឹងពលករឡាវដែរ ។ ស្ត្រីភាគច្រើនមិនសូវមានចំណេះដឹង ត្រូវបានបង្ខំឲ្យរៀបការជាមួយបុរសចិនចំណាស់ៗ ហើយនៅពេលពួកគាត់រងគ្រោះបញ្ជូនមកពីចិនវិញ ត្រូវបានយកដាក់មណ្ឌល ពួកគាត់មិនចង់ត្រឡប់ទៅផ្ទះវិញទេ គឺចង់នៅធ្វើការនៅតាមភោជនីយដ្ឋាន និងកន្លែងផ្សេងៗ ។ តែករណីចង់ធ្វើការនេះត្រូវបានអង្គការពិនិត្យមើលប្រវត្តិ និងសមត្ថភាពផងដែរ ។

<u>**ក្រុមទី៤ ៖ ការពង្រឹងការអនុវត្តច្បាប់**</u>

- សុវត្ថិភាពទេសន្តរប្រវេសន៍មិនទាន់ត្រូវបានការពារឲ្យបានល្អ ។
- ការការពារ និងគ្រប់គ្រងព្រំដែន គឺពាក់ព័ន្ធសិទ្ធិសេរីភាពរបស់ពលករ មិនអាចហាមឃាត់មិនឲ្យចេញ ដូច្នេះគាត់នៅតែទៅ នាំឲ្យមានការគ្រប់គ្រងពិបាក ព្រោះព្រំដែនគោក និងទឹក ។ ពិបាកមិនដឹងមេខ្យល់នាំទៅតាមណា ។
- ប្រទេសគោលដៅដាក់ច្បាប់ហើយតែមិនទាន់អនុវត្ត ការអនុវត្តត្រឹមតែពិន័យផ្នែករដ្ឋបាល ។ បើគេអនុវត្តមែន នឹងមានការចាប់ខ្លួន ត្រូវរត់គេច ឬ ត្រឡប់មកវិញ ។
- កិច្ចសហការរវាងប្រទេសបញ្ជូន និងទទួលក្នុងការអនុវត្តកិច្ចព្រមព្រៀង ធ្វើមិនបានល្អ មានតែនៅលើកិច្ចព្រមព្រៀង ។ មានកិច្ចសហការក្រៅផ្លូវការច្រើន ដែលត្រូវដោះស្រាយបន្ទាន់ ។

<u>អនុសាសន៍៖</u>

- វិធានការ ប្រកបដោយការប្តេជ្ញាចិត្តជានយោបាយ រវាងប្រទេសបញ្ជូន និងប្រទេសទទួល ។
- ត្រូវការឲ្យមានកិច្ចសហការក្នុងអនុវត្តរួមគ្នា ជាកិច្ចប្រតិបត្តិការរួម ដើម្បីបង្ការទប់ស្កាត់ និងការជួយ

សង្គ្រោះ ដែលមានលក្ខណៈជាស្តង់ដាតែមួយ ។

- ពង្រឹងសមត្ថភាពសមត្ថកិច្ចទាំងសងខាងរវាងប្រទេសបញ្ជូន និងប្រទេសទទួល ក្នុងការអនុវត្តច្បាប់ ឲ្យបានត្រឹមត្រូវ ។
- លើកទឹកចិត្តក្នុងកិច្ចសហការក្រៅផ្លូវការដើម្បីជួយដល់ជនរងគ្រោះ ។
- បង្កើនលទ្ធភាពជួយជនរងគ្រោះ ក្នុងការទទួលបានសំណង ។
- ឡាវ ៖ ការអនុវត្តឲ្យមានប្រសិទ្ធភាពគឺមានតែការជួយឲ្យចេញទៅដោយស្របច្បាប់ ព្រោះមិនមានជម្រើសផ្សេង ដោយអាចហាមឃាត់បាន ហើយព្រំដែនយើងជាព្រំដែនគោកពិបាកគ្រប់គ្រង តែយើងត្រូវតែព្យាយាមសហការទប់ស្កាត់មិនឲ្យមានការចេញខុសច្បាប់ ។ ប៉ូលីសមានល្អ មានមិនល្អ ដូច្នេះត្រូវធ្វើការលើកទឹកចិត្តប៉ូលីស ។ ខ្ញុំសូមស្នើប្រទេសគោលដៅជួយ និងអនុវត្តឲ្យបានត្រឹមត្រូវ ។ យើងនឹងជួយពន្លឿនការចុះឈ្មោះពលករឲ្យបានលឿន ។

**ខណ្ឌទី ៤** : ការបែងចែកក្រុមពិភាក្សា ដើម្បីកំណត់អាទិភាពជាយុទ្ធសាស្ត្រ និងដំណោះស្រាយរួម

ក្រុមទី១ ៖ យន្តការ ឬប្រព័ន្ធការពារពលករទេសន្តរប្រវេសន៍ ដែលប្រឈមនឹងហានិភ័យ

- អនុវត្តតាមប្រទេស ៖
  - ជំរុញការអនុវត្តយន្តការដែលមានស្រាប់ ដោយយន្តការអនុវត្តមិនទាន់បានល្អ
  - ផ្សព្វផ្សាយបន្តអំពីចំណាកស្រុកខុសច្បាប់ ផលវិបាកនៃការស្នាក់នៅ និងធ្វើការខុសច្បាប់
  - កាត់បន្ថយពេលវេលា និងតម្លៃនៃការធ្វើឯកសារ
  - ពង្រឹងប្រសិទ្ធភាពការអនុវត្តច្បាប់
  - ធ្វើការរួមគ្នារវាងរដ្ឋាភិបាល និងអង្គការ
  - ពង្រីកបន្ថែមមណ្ឌលព័ត៌មាន និងសេវា
  - រឹតបន្តឹងការត្រួតពិនិត្យតាមព្រំដែន
  - បន្ថែមប្រាក់ឈ្នួលដល់ពលករដែលធ្វើការក្នុងស្រុក ។
- ការសហការ ៖
  - ផ្តល់ព័ត៌មាន និងបទពិសោធន៍ អោយគ្នាតាមរយៈកិច្ចប្រជុំ
  - បង្កើតជនបង្គោលសម្រាប់ទំនាក់ទំនង
  - បង្កើតយន្តការរួមប្រទេសបញ្ជូន និងពិភាក្សាបញ្ហាថ្មីៗ
  - បង្កើតប្រព័ន្ធទិន្នន័យចេញចូល ។

ក្រុមទី២ ៖ ការទប់ស្កាត់

- អនុវត្តតាមប្រទេស ៖
  - ការបណ្តុះបណ្តាលមុនចាកចេញ
  - បន្តធ្វើសកម្មភាពទេសន្តរប្រវេសន៍ដោយសុវត្ថិភាព ផ្សព្វផ្សាយអំពីទេសន្តរប្រវេសន៍
  - បង្កើនឱកាសការងារក្នុងប្រទេសរៀងៗខ្លួន
  - លើកទឹកចិត្តវិនិយោគក្នុងស្រុក
  - បង្កើនការកសាងជំនាញ : យើងបានកំពុងធ្វើ និងបន្ត
  - ការចូលរួមពីដៃគូឯកជន ដើម្បីផ្តល់ឱកាសការងារ

- បន្តកសាងសមត្ថភាពមន្ត្រីពាក់ព័ន្ធព្រំដែន បានធ្វើ និងបន្តទៀត
- ការជ្រើសរើសប្រកបដោយក្រមសីលធម៌
- សម្រួលការធ្វើដំណើរ និងសេវាឯកសារ
- <u>មីយ៉ាន់ម៉ា</u> ៖ គោលនយោបាយពេលខ្លះផ្លាស់ប្តូរ នាំឲ្យមិនទុកចិត្ត មីយ៉ាន់ម៉ា សុំឲ្យមានការជឿទុកចិត្ត គោលនយោបាយ សុំឲ្យរដ្ឋាភិបាលកុំផ្លាស់ប្តូរគោលនយោបាយលឿន ។

• ការសហការ ៖

- សុំឲ្យមានកិច្ចប្រជុំប្រទេសបញ្ជូន និងប្រទេសគោលដៅ
- ការចែកចាយព័ត៌មានឆាប់រហ័ស
- គោលនយោបាយរួម និយមន័យរួម
- សុំឲ្យប្រទេសទាំងអស់ពិភាក្សា និងសហការគ្នា ដើម្បីឲ្យការអនុវត្តស៊ីចង្វាក់ ។

<u>ក្រុមទី៣</u> ៖ ការការពារជនរងគ្រោះ

• អនុវត្តតាមប្រទេស ៖

- ពង្រឹងការសហការក្នុងការចែករំលែកព័ត៌មានជនរងគ្រោះ និងរក្សាការសម្ងាត់ជនរងគ្រោះ
- បង្កើតទិន្នន័យអនឡាន ដែលត្រូវធ្វើដោយក្រសួងសង្គមកិច្ច
- ចង់ឲ្យមានការកំណត់អត្តសញ្ញាណជនរងគ្រោះដូចៗគ្នា បណ្តុះបណ្តាលមន្ត្រីពាក់ព័ន្ធ និងមានកញ្ចប់សម្រាប់ការធ្វើមាតុភូមិនិវត្តន៍
- ជំរុញប្រព័ន្ធធ្វើសមាហរណកម្មឲ្យប្រសើរឡើង (មានថវិកា និងការបណ្តុះបណ្តាល)
- ពន្លឿនការរៀបចំឯកសារផ្លូវច្បាប់
- ការកំណត់អត្តសញ្ញាណជនរងគ្រោះនៅច្រកចេញចូលតែមួយ និងសំណាងជនរងគ្រោះ
- <u>ឡាវ</u> ៖ គួរមាន SOP
- <u>មីយ៉ាន់ម៉ា</u> ៖ នៅមានកង្វះខាតថវិកាបម្រុងទុក ។

• ការសហការ ៖

- គួរមានកិច្ចប្រជុំរួមគ្នាទៀងទាត់
- ធ្វើការចែកចាយព័ត៌មានជាប្រព័ន្ធ
- បង្កើតជនបង្គោលតាមប្រទេសនីមួយៗ ដើម្បីទំនាក់ទំនង ។

<u>ក្រុមទី៤</u> ៖ ការពង្រឹងការអនុវត្តច្បាប់

• អនុវត្តតាមប្រទេស ៖

- ពន្លឿនការអនុម័តច្បាប់
- ពន្លឿនជំនួយច្បាប់ក្នុងរឿងក្តីព្រហ្មទណ្ឌ
- ពង្រឹងក្របខណ្ឌនៃការអនុវត្ត

• ការសហការ ៖

- ជំរុញ និងពង្រឹងកិច្ចសហប្រតិបត្តិការក្រៅផ្លូវការរវាងប្រទេសបញ្ជូន និងប្រទេសទទួល តាមរយៈអង្គភាពឯកទេស
- បង្កើតកិច្ចព្រមព្រៀងរួមក្នុងការកំណត់អត្តសញ្ញាណ ។

**ឃ. កម្មវិធីបិទ**

លោក Onevong Keobunnavong ប្រធានគណៈប្រតិភូឡាវ បានមានប្រសាសន៍ថា៖ សូមថ្លែងអំណរគុណជាថ្មីចំពោះគណៈប្រតិភូទាំងអស់ យើងបានយល់អំពីបញ្ហាប្រឈមទាំងឡាយ និងបានបំពេញនូវអ្វីដែលយើងត្រូវការ ។ ពេលត្រឡប់ទៅវិញ ខ្ញុំនឹងពាំនាំយកលទ្ធផលនៃកិច្ចប្រជុំនេះ ទៅរាយការណ៍ជូនថ្នាក់ដឹកនាំ និងធ្វើការពិភាក្សាឲ្យកាន់តែស៊ីជម្រៅ ព្រមទាំងធ្វើការផ្សព្វផ្សាយបន្ថែម ដើម្បីឲ្យការងាររបស់យើងកាន់តែឆាប់ទទួលបានជោគជ័យ ។

លោកស្រី Thin Pyant Thida Kyaw ប្រធានគណៈប្រតិភូមីយ៉ាន់ម៉ា បានមានប្រសាសន៍ថា៖ សូមថ្លែងអំណរគុណជាថ្មីចំពោះគណៈប្រតិភូទាំងអស់ ហើយខ្ញុំសប្បាយរីករាយណាស់ដែលបានចូលរួមកិច្ចប្រជុំពិភាក្សាអំពីការងារពាក់ព័ន្ធនឹងពលករទេសន្តរប្រវេសន៍នេះ ។

**លោកជំទាវ ជូ ប៊ុនអេង** បានមានប្រសាសន៍ថា៖ ក្នុងនាមរដ្ឋាភិបាលកម្ពុជា និងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ខ្ញុំសូមថ្លែងអំណរគុណចំពោះវត្តមានដ៏មានតម្លៃ ដែលគណៈ ប្រតិភូទាំងអស់ និងអង្គការដៃគូបានចូលរួម ក្នុងគោលបំណងការពារ និងយកចិត្តទុកដាក់ចំពោះប្រជាពលរដ្ឋ ។ នៅក្នុងកិច្ចប្រជុំនេះ យើងមានបីប្រទេសចូលរួម កម្ពុជា ឡាវ និងមីយ៉ាន់ម៉ា ដោយបានរកឃើញនូវបញ្ហាប្រឈម និងដំណោះស្រាយផ្សេងៗ និងបានឯកភាពគ្នាថានឹងធ្វើការនេះបន្តទៅមុខទៀត ដើម្បីទទួលបានជោគជ័យ ។ ខ្ញុំសង្ឃឹមថា លទ្ធផលកិច្ចប្រជុំនេះនឹងយកទៅដាក់នៅប្រទេសរៀងខ្លួនធ្វើការពិភាក្សា ជាពិសេសថ្នាក់ដឹកនាំរដ្ឋាភិបាល ដែលអាចនឹងបន្ថែមនូវចំណុចខ្វះចន្លោះឲ្យកាន់តែប្រសើរ ។ សូមថ្លែងអំណរគុណចំពោះការចំណាយពេលវេលារបស់គណៈប្រតិភូ និងភ្ញៀវទាំងអស់ដែលបានចូលរួម និងសូមជូនពរឲ្យការងាររបស់យើងទទួលបានលទ្ធផលឆាប់ៗ ។

ជាកិច្ចបញ្ចប់នៃកិច្ចប្រជុំ ប្រធានគណៈប្រតិភូតំណាងឲ្យរដ្ឋាភិបាលនៃប្រទេសទាំងបី កម្ពុជា ឡាវ និងមីយ៉ាន់ម៉ា បានធ្វើការចុះហត្ថលេខាលើកំណត់ហេតុនៃកិច្ចប្រជុំដែលបានឯកភាពគ្នា ក្នុងបរិយាកាសរីករាយ និងស្និទ្ធស្នាល នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨ នៅខេត្តសៀមរាប ព្រះរាជាណាចក្រកម្ពុជា ។

**សូមគោរពជូន លោកជំទាវ**
**អនុប្រធានអចិន្ត្រៃយ៍ មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់**
ថ្ងៃច័ន្ទ ១៤កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធស័ក ព.ស២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ២០១៨
**អ្នកធ្វើកំណត់ហេតុ**

វរសេនីយ៍ទោ. **ហ៊ី រតនៈ**

**បានឃើញ និងគោរពជូន សម្តេចក្រឡាហោម**
**មេត្តាជ្រាប និងផ្តល់អនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់**
ថ្ងៃព្រ.ហ ២រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធស័ក ព.ស២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១៨
**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

ជូ ប៊ុនអេង